# គាថានមស្ការ



# ការផ្សាយរបស់ពុទ្ធិកបណ្ឌិតសភា
# នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា

*ប្រមូលចងក្រងដោយខេមរ អភិធម្មាវតារ*

*ព.ស. ២៥៦៤*

## គាថានមស្ការ

# ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាប្រទីបក្នុងលោក

ពុទ្ធោ តិលោកទីបោវ, ពុទ្ធោ សុរិយោ តមោនុទោ;
យេ យន្តិ សរណំ ពុទ្ធំ, នត្ថិ តេសំ ភយំ សទា ។

*ព្រះពុទ្ធជាប្រទីបក្នុងត្រៃលោក ព្រះអង្គដូចជាព្រះអាទិត្យ អាចកម្ចាត់បង់នូវងងឹតគឺអវិជ្ជា, ជនទាំងឡាយឯណាបានដល់ព្រះពុទ្ធជាទីពឹងទីរលឹក, ភ័យមិនមានដល់ជនទាំងឡាយនោះសព្វៗកាល ។*

ធម្មោ តិលោកទីបោវ, ធម្មោ សុរិយោ តមោនុទោ;
យេ យន្តិ សរណំ ធម្មំ, នត្ថិ តេសំ ភយំ សទា ។

*ព្រះសទ្ធម្មជាប្រទីបក្នុងត្រៃលោក ព្រះសទ្ធម្មនោះឯងជាព្រះអាទិត្យ អាចកម្ចាត់បង់នូវសេចក្ដីងងឹត គឺអវិជ្ជា, ជនទាំងឡាយឯណា បានដល់នូវព្រះសទ្ធម្មជាទីពឹងទីរលឹក, ភ័យមិនមានដល់ជនទាំងឡាយនោះសព្វៗកាល ។*

សង្ឃោ តិលោកទីបោវ, សង្ឃោ សុរិយោ តមោនុទោ;
យេ យន្តិ សរណំ សង្ឃំ, នត្ថិ តេសំ ភយំ សទា ។

*ព្រះសង្ឃជាប្រទីបក្នុងត្រៃលោក ព្រះសង្ឃនោះឯងជាព្រះអាទិត្យ អាចកម្ចាត់បង់នូវងងឹត គឺអវិជ្ជា ជនទាំងឡាយឯណា បានដល់នូវព្រះសង្ឃជាទីពឹងទីរលឹក ភ័យមិនមានដល់ជនទាំងឡាយនោះសព្វៗកាល ។*

យោ ច ពុទ្ធញ្ច ធម្មញ្ច, សង្ឃញ្ច សរណំ គតោ;
អបទីបោ ន ភវេយ្យ, អធិគច្ឆេយ្យ បទំ សុខំ ។

*បើនរណាមួយ បានដល់នូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទីពឹងទីរលឹកហើយ, នរជននោះ ឈ្មោះថាជាអ្នកមានប្រទីប គឺបញ្ញា ហើយបាននូវព្រះនិព្វានជាបរមសុខដ៏ក្រៃលែង ។*

*(ទុលកបណ្ឌិតជាតក បញ្ញាសជាតក)*

គាថានមស្ការ

# ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃជាពាក្យដ៏ប្រសើរ

ពុទ្ធោតិ វចនំ សេដ្ឋំ, ពុទ្ធោតិ បទ មុត្តមំ;
នត្ថិ តេន សមំ លោកេ, អញ្ញំ សោតរសាយនំ។

*ពាក្យថា* **ពុទ្ធោ** *ជាពាក្យដ៏ប្រសើរវិសេស ពាក្យថា* **ពុទ្ធោ** *ជាពាក្យដ៏ឧត្តមពិត, ពាក្យដទៃ ដែលជាទីនាំមកនូវរសដល់ត្រចៀកអ្នកស្តាប់ក្នុងលោក ស្មើដោយពាក្យថា* **ពុទ្ធោ** *ពុំមានឡើយ ។*

ធម្មោតិវចនំ សេដ្ឋំ, ធម្មោតិ បទមុត្តមំ;
នត្ថិ តេន សមំ លោកេ, អញ្ញំ សោតរសាយនំ។

*ពាក្យថា* **ធម្មោ** *ជាពាក្យដ៏ប្រសើរវិសេស ពាក្យថា* **ធម្មោ** *ជាពាក្យដ៏ឧត្តមពិត, ពាក្យដទៃ ដែលជាទីនាំមកនូវរសដល់ត្រចៀកអ្នកស្តាប់ក្នុងលោក ស្មើដោយពាក្យថា* **ធម្មោ** *ពុំមានឡើយ ។*

សង្ឃោតិ វចនំ សេដ្ឋំ, សង្ឃោតិ បទមុត្តមំ;
នត្ថិ តេន សមំ លោកេ, អញ្ញំ សោតរសាយនំ។

*ពាក្យថា* **សង្ឃោ** *ជាពាក្យដ៏ប្រសើរវិសេស ពាក្យថា* **សង្ឃោ** *ជាពាក្យដ៏ឧត្តមពិត, ពាក្យដទៃ ដែលជាទីនាំមកនូវរសដល់ត្រចៀកអ្នកស្តាប់ក្នុងលោក ស្មើដោយពាក្យថា* **សង្ឃោ** *ពុំមានឡើយ ។*

តស្ស មុខំ មុខំ នាម, យំ វត្តតិ មុខេ សទា;
ទុល្លភំ ពុទ្ធវចនំ, សព្វសម្បត្តិទាយកំ។

# គាថានមស្ការ

*ពាក្យថា* **ព្រះពុទ្ធ** *ជាពាក្យដែលសត្វលោករកបានដោយក្រ អាចឲ្យនូវសម្បត្តិទាំងពួង ប្រព្រឹត្តទៅក្នុងមាត់នៃបុគ្គលណាសព្វ ៗ កាល, មាត់របស់បុគ្គលនោះ បានឈ្មោះថា មាត់ល្អប្រពៃ មាត់មានលាភដោយពិត ។*

តស្ស មនោ មនោ នាម, យំ ចេ មនសិ វត្តតិ;
ទុល្លភំ ពុទ្ធវចនំ, សព្ពសម្បត្តិទាយកំ។

*ពាក្យថា* **ព្រះពុទ្ធ** *ជាពាក្យដែលសត្វលោករកបានដោយក្រ អាចឲ្យនូវសម្បត្តិទាំងពួង ប្រព្រឹត្តទៅក្នុងចិត្តបុគ្គលណាហើយ ចិត្តរបស់បុគ្គលនោះ បានឈ្មោះថា ចិត្តល្អប្រពៃ ចិត្តមានលាភដោយពិត។*

តស្សេវ សោតំ សោតំវ, យំ សុណាតិ ជនោ អយំ
ទុល្លភំ ពុទ្ធវចនំ, សព្ពសម្បត្តិទាយកំ។

*បុគ្គលណាបានស្តាប់នូវពាក្យថា* **ព្រះពុទ្ធ** *ជាពាក្យដែលបុគ្គលរកបានដោយក្រ អាចឲ្យនូវសម្បត្តិទាំងពួងដូច្នេះថា: "បុគ្គលនេះ ជាអង្គព្រះជិនស្រី" សោតប្បសាទរបស់បុគ្គលនោះបានឈ្មោះថា សោតប្បសាទល្អប្រពៃ សោតប្បសាទមានលាភដោយពិត ។*

*(មធុរសវាហិនី ធម្មសោណ្ឌកវគ្គ អហិតុណ្ឌិកវត្ថុកថា)*

# គាថានមស្ការព្រះពុទ្ធជាបុរសអាជានេយ្យ

(បែបសង្ខេប)

នមោ តេ បុរិសាជញ្ញ, នមោ តេ បុរិសុត្តម;

សព្វញ្ញូសិ មហាវីរ, លោកជេដ្ឋ នរាសភ ។

បពិត្រព្រះអង្គជាបុរសជានេយ្យ ខ្ញុំសូមនមស្ការព្រះអង្គ

បពិត្រព្រះអង្គជាបុរសដ៏ឧត្តម ខ្ញុំសូមនមស្ការព្រះអង្គ

បពិត្រព្រះអង្គទ្រង់មានព្យាយាមធំ ជាបុគ្គលខ្ពង់ខ្ពស់ជាងសត្វលោក

ប្រសើរជាងនរជន ព្រះអង្គជាព្រះសព្វញ្ញូពុទ្ធ ។

*(សុត្តន្តបិដក ខុទ្ទកនិកាយ អបទាន បទុមកេសរវគ្គ អាសនសន្ថវិកត្ថេរស្សាបទាន បិដក ៧៤ ទំព័រ ១៩)*

នមោ តេ បុរិសាជញ្ញ, នមោ តេ បុរិសុត្តម;

ពហុជ្ជនំ តារយសិ, ទេសេន្តោ អមតំ បទំ ។

បពិត្រព្រះអង្គជាបុរសអាជានេយ្យ ខ្ញុំសូមនមស្ការព្រះអង្គ

បពិត្រព្រអង្គជាបុរសដ៏ឧត្តម ខ្ញុំសូមនមស្ការព្រះអង្គ

ព្រះអង្គកាលសម្តែងនូវអមតបទ គឺព្រះនិព្វាន

ញុំាំងជនដ៏ច្រើន ឲ្យឆ្លងវដ្តទុក្ខបាន ។

*(សុត្តន្តបិដក ខុទ្ទកនិកាយ អបទាន ថោមកវគ្គ ថោមកត្ថេរស្សាបទាន បិដក ៧៣ ទំព័រ ១៨៨)*

# គាថានមស្ការ

រូបេ សីលេ សមាធិម្ហិ, បញ្ញាយ ច អសាទិសោ;

វិមុត្តិយា អសមសមោ, ធម្មចក្កប្បវត្តនេ ។

*ព្រះអង្គមិនមានបុគ្គលស្មើ ក្នុងព្រះរូបផង សីលផង សមាធិផង បញ្ញាផង*

*ព្រះអង្គស្មើដោយព្រះពុទ្ធទាំងឡាយ ដែលមិនមានបុគ្គលស្មើ*

*ចំពោះវិមុត្តិធម៌ និងការញ៉ាំងធម្មចក្កឲ្យប្រព្រឹត្តទៅ ។*

*(សុត្តន្តបិដក ខុទ្ទកនិកាយ ពុទ្ធវំស រតនចង្កមនកណ្ឌ បិដកលេខ ៧៧ ទំព័រ ១៣)*

លាភាលាភេ ន សជ្ជន្តិ, សម្មានេនវិមានេន;

បឋវីសទិសា ពុទ្ធា, តស្មា តេ ន វិរាធិយា ។

*ព្រះពុទ្ធទាំងឡាយមានចិត្តស្មើដោយផែនដី មិនជាប់ជំពាក់ក្នុងលាភ និងអលាភ ក្នុងការរាប់អាន ក្នុងការមើលងាយ ហេតុនោះ បុគ្គលមិនគប្បីឲ្យឆ្គាំឆ្គងនឹងព្រះពុទ្ធទាំងនោះឡើយ ។*

*(សុត្តន្តបិដក ខុទ្ទកនិកាយ អបទាន ពុទ្ធវគ្គ ឧបាលិត្ថេរអបទាន បិដក ៧២ ទំព័រ១០៨)*

# គាថានមស្ការព្រះពុទ្ធជាបុរសអាជានេយ្យ

## (បែបពិស្តារ)

នមោ តេ បុរិសាជញ្ញ, នមោ តេ បុរិសុត្តម;
សព្វញ្ញូសិ មហាវីរ, លោកជេដ្ឋ នរាសភ។

បពិត្រព្រះអង្គជាបុរសជានេយ្យ ខ្ញុំសូមនមស្ការព្រះអង្គ
បពិត្រព្រះអង្គជាបុរសដ៏ឧត្តម ខ្ញុំសូមនមស្ការព្រះអង្គ
បពិត្រព្រះអង្គទ្រង់មានព្យាយាមធំ ជាបុគ្គលខ្ពង់ខ្ពស់ជាងសត្វលោក
ប្រសើរជាងនរជន ព្រះអង្គជាព្រះសព្វញ្ញូពុទ្ធ ។

*(សុត្តន្តបិដក ខុទ្ទកនិកាយ អបទាន បទុមកេសរវគ្គ អាសនសន្ថវិកត្ថេរស្សាបទាន បិដក ៧៤ ទំព័រ ១៩)*

នមោ តេ បុរិសាជញ្ញ, នមោ តេ បុរិសុត្តម;
ពហុជ្ជនំ តារយសិ, ទេសេន្តោ អមតំ បទំ។

បពិត្រព្រះអង្គជាបុរសអាជានេយ្យ ខ្ញុំសូមនមស្ការព្រះអង្គ
បពិត្រព្រអង្គជាបុរសដ៏ឧត្តម ខ្ញុំសូមនមស្ការព្រះអង្គ
ព្រះអង្គកាលសម្តែងនូវអមតបទ គឺព្រះនិព្វានញ៉ាំងជនដ៏ច្រើន
ឲ្យឆ្លងវដ្តទុក្ខបាន ។

*(សុត្តន្តបិដក ខុទ្ទកនិកាយ អបទាន ថោមកវគ្គ ថោមកត្ថេរស្សាបទាន បិដក ៧៣ ទំព័រ ១៨៤)*

# គាថានមស្ការ

នមោ តេ បុរិសាជញ្ញ, នមោ តេ បុរិសុត្តម;
កុសលេន សមេក្ខសិ, អមនុស្សាបិ តំ វន្ទន្តិ;
សុតំ នេតំ អភិណ្ហសោ, តស្មា ឯវំ វទេមសេ។

បពិត្រព្រះអង្គជាបុរសអាជានេយ្យ ខ្ញុំសូមនមស្ការចំពោះព្រះអង្គ បពិត្រព្រះអង្គជាបុរសដ៏ឧត្តម ខ្ញុំសូមនមស្ការចំពោះព្រះអង្គ សូម្បីអមនុស្សទាំងឡាយ ក៏រមែងថ្វាយបង្គំព្រះអង្គថា ព្រះអង្គទតព្រះនេត្រមើលមហាជនដោយសព្វញ្ញុតញ្ញាណដ៏ផូរផង់។

(*សុត្តន្តបិដក ទីឃនិកាយ បាដិកវគ្គ អាដានាដិយសូត្រ បិដកលេខ ១៩ ទំព័រ ១០២*)

នមោ តេ បុរិសាជញ្ញ, នមោ តេ បុរិសុត្តម;
អត្តានំ តារយិត្វាន, បរេ តារេសិ តំ មុនិ។

បពិត្រព្រះអង្គជាបុរសអាជានេយ្យ ខ្ញុំសូមនមស្ការចំពោះព្រះអង្គ បពិត្រព្រះអង្គជាបុរសដ៏ឧត្តម ខ្ញុំសូមនមស្ការចំពោះព្រះអង្គ បពិត្រព្រះមុនី ព្រះអង្គទ្រង់ធ្វើព្រះអង្គឲ្យត្រេកអរ ហើយធ្វើអ្នកដទៃឲ្យត្រេកអរផង ។

( *សុត្តន្តបិដក ខុទ្ទកនិកាយ អបទាន ភិក្ខុទាយិវគ្គ សុមង្គលត្ថេរស្សាបទាន បិដក ៧៣ ទំព័រ ១៧* )

នមោ តេ បុរិសាជញ្ញ, នមោ តេ បុរិសុត្តម;
សទេវកស្មិំ លោកស្មិំ, នត្ថិ តេ បដិបុគ្គលោ។

បពិត្រព្រះអង្គជាបុរសអាជានេយ្យ ខ្ញុំសូមនមស្ការចំពោះព្រះអង្គ, បពិត្រព្រះអង្គជាបុរសដ៏ឧត្តម ខ្ញុំសូមនមស្ការចំពោះព្រះអង្គ, ព្រះអង្គមិនមានបុគ្គលប្រៀបផ្ទឹម ក្នុងលោកព្រមទាំងទេវលោក ។

# គាថានមស្ការ

នមោ តេ បុរិសាជញ្ញ, នមោ តេ បុរិសុត្តម;
យស្ស តេ អាសវា ខីណា, ទក្ខិណេយ្យោសិ មារិស ។

*បពិត្របុរសអាជានេយ្យ ខ្ញុំសូមនមស្ការចំពោះព្រះអង្គ បពិត្របុរសដ៏ឧត្តម ខ្ញុំសូមនមស្ការចំពោះព្រះអង្គ ដែលមានអាសវៈអស់ហើយ ព្រះអង្គទ្រង់និរទុក្ខ ព្រះអង្គជាអ្នកគួរទទួលទក្ខិណាទាន ៕*

*( យកអត្ថន័យតាមសុត្តន្តបិដក ខុទ្ទកនិកាយ ថេរគាថា)*

រូបេ សីលេ សមាធិម្ហិ, បញ្ញាយ ច អសាទិសោ;
វិមុត្តិយា អសមសមោ, ធម្មចក្កប្បវត្តនេ ។

*ព្រះអង្គមិនមានបុគ្គលស្មើ ក្នុងព្រះរូបផង សីលផង*
*សមាធិផង បញ្ញាផង ព្រះអង្គស្មើដោយព្រះពុទ្ធទាំងឡាយ*
*ដែលមិនមានបុគ្គលស្មើ ចំពោះវិមុត្តិធម៌*
*និងការញ៉ាំងធម្មចក្កឲ្យប្រព្រឹត្តទៅ ។*

*( សុត្តន្តបិដក ខុទ្ទកនិកាយ ពុទ្ធវំស រតនចង្កមនកណ្ឌ បិដកលេខ ៧៧ ទំព័រ ១៣)*

លាភាលាភេ ន សជ្ជន្តិ, សម្មានេ វិមានេ;
បថវីសទិសា ពុទ្ធា, តស្មា តេ ន វិរាធិយា ។

*ព្រះពុទ្ធទាំងឡាយមានចិត្តស្មើដោយផែនដី មិនជាប់ជំពាក់ក្នុងលាភ និងអលាភ ក្នុងការរាប់អាន ក្នុងការមើលងាយ ហេតុនោះ បុគ្គលមិនគប្បីឲ្យឆ្គាំឆ្គងនឹងព្រះពុទ្ធទាំងនោះឡើយ ។*

*( សុត្តន្តបិដក ខុទ្ទកនិកាយ អបទាន ពុទ្ធវគ្គ ឧបាលិត្ថេរអបទាន បិដក ៧២ ទំព័រ១០៨)*

# គាថា នមោ តេ បុរិសាជញ្ញ (ដល់សាវក)

នមោ តេ បុរិសាជញ្ញ, នមោ តេ បុរិសុត្តម;
យស្ស តេ អាសវា ខីណា, ទក្ខិណេយ្យោសិ មារិស។

*បពិត្រលោកជាបុរសអាជានេយ្យ ខ្ញុំសូមថ្វាយបង្គំចំពោះលោក បពិត្រលោកជាបុរសដ៏ខ្ពង់ខ្ពស់ ខ្ញុំសូមថ្វាយបង្គំចំពោះលោក បពិត្រលោកនិរទុក្ខ អាសវៈទាំងឡាយ របស់លោកណាអស់ហើយ លោកនោះ ជាទក្ខិណេយ្យបុគ្គល ។*

*(សុត្តន្តបិដក ខុទ្ទកនិកាយ ថេរគាថា ទ្វាទសកនិបាត សុនីតត្ថេរគាថា បិដកលេខ ៥៧ ទំព័រ ៣០)*

នមោ តេ បុរិសាជញ្ញ, នមោ តេ បុរិសុត្តម;
យស្ស តេ នាភិជានាម, យម្បិ និស្សាយ ឈាយតិ ។

*បពិត្របុរសអាជានេយ្យ ខ្ញុំសូមក្រាបថ្វាយបង្គំលោកម្ចាស់ បពិត្របុរសដ៏ឧត្តម ខ្ញុំសូមក្រាបថ្វាយបង្គំលោកម្ចាស់ លោកម្ចាស់ចម្រើនឈាន អាស្រ័យអារម្មណ៍ណា ពួកយើងខ្ញុំមិនបានដឹងនូវអារម្មណ៍នោះ របស់លោកម្ចាស់ទេ ។*

*(សុត្តន្តបិដក ខុទ្ទកនិកាយ ថេរគាថា ចត្តាឡីសនិបាត មហាកស្សបត្ថេរគាថា បិដកលេខ ៥៧ ទំព័រ ១០៣)*

# គាថានមស្ការ

# ព្រះពុទ្ធប្រព្រឹត្តដើម្បីប្រយោជន៍ដល់សត្វលោក

- *ពុទ្ធោ សោ ភគវា ពោធាយ ធម្មំ ទេសេតិ ព្រះមានព្រះភាគអង្គនោះ ទ្រង់ត្រាស់ដឹង (ដោយព្រះអង្គឯង) ហើយទ្រង់សម្ដែងធម៌ដើម្បីញុំាងបុគ្គលដទៃឲ្យត្រាស់ដឹងផង ។*
- *ទន្តោ សោ ភគវា ទមថាយ ធម្មំ ទេសេតិ ព្រះមានព្រះភាគអង្គនោះ ទ្រង់ទូន្មានព្រះអង្គបានហើយ ទ្រង់សម្ដែងធម៌ដើម្បីទូន្មានអ្នកដទៃផង ។*
- *សន្តោ សោ ភគវា សមថាយ ធម្មំ ទេសេតិ ព្រះមានព្រះភាគអង្គនោះទ្រង់ស្ងប់ហើយ ទើបសម្ដែងធម៌ ដើម្បីសេចក្ដីស្ងប់ដល់អ្នកដទៃ ។*
- *តិណ្ណោ សោ ភគវា តរណាយ ធម្មំ ទេសេតិ ព្រះមានព្រភាគអង្គនោះ ទ្រង់ឆ្លងផុតហើយ ទើបសម្ដែងធម៌ ដើម្បីការឆ្លងដល់អ្នកដទៃ ។*
- *បរិនិព្វុតោ សោ ភគវា បរិនិព្វាណាយ ធម្មំ ទេសេតិ ព្រះមានព្រះភាគអង្គនោះ ទ្រង់រំលត់កិលេសបានហើយទើបសម្ដែងធម៌ដើម្បីសេចក្ដីរំលត់កិលេសដល់អ្នកដទៃ ។*

*(សុត្តន្តបិដក ទីឃនិកាយ បាថិកវគ្គ ឧទុម្ពរិកសូត្រ )*

គាថានមស្ការ

# មហាបដិញ្ញា

## (ការប្តេជ្ញាធំរបស់ព្រះពោធិសត្វ)

| | |
|---|---|
| ១. តិណ្ណោ តារយេយ្យំ | *យើងឆ្លងផុតហើយ នឹងឲ្យអ្នកដទៃឆ្លងផុតផង* |
| ២. មុត្តោ មោចេយ្យំ | *យើងរួចផុតហើយ នឹងឲ្យអ្នកដទៃរួចផុតផង* |
| ៣. ពុទ្ធោ ពោធេយ្យំ | *យើងត្រាស់ដឹងហើយ នឹងឲ្យអ្នកដទៃត្រាស់ដឹងផង* |
| ៤. សុទ្ធោ សោធេយ្យំ | *យើងបរិសុទ្ធហើយ នឹងឲ្យអ្នកដទៃបរិសុទ្ធិផង* |
| ៥. ទន្តោ ទមេយ្យំ | *យើងទូន្មានបានហើយ នឹងឲ្យអ្នកដទៃទូន្មានបានផង* |
| ៦. សន្តោ សមេយ្យំ | *យើងស្ងប់ហើយ នឹងឲ្យអ្នកដទៃស្ងប់ផង* |
| ៧. អស្សត្ថោ អស្សាសេយ្យំ | *យើងរីងស្ងួតហើយ នឹងឲ្យអ្នកដទៃរីងស្ងួតផង* |
| ៨. បរិនិព្វុតោ បរិនិព្វាបេយ្យំ | *យើងបរិនិព្វានហើយ នឹងឲ្យអ្នកដទៃបរិនិព្វានផង។* |